# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

(ASPIRE)

IFAD Loan No. 2000000744 និងASAP Trust Grant No. 2000000743

# គោលការណ៍ណែនាំ

# សម្រាប់បង្កើតបណ្តុំអាជីវកម្ម



ភ្នំពេញ ខែ ឧសភា ឆ្នាំ ២០១៧

**រៀបចំដោយ** : លេខាធិការដ្ឋាន នៃកម្មវិធី (ASPIRE)

**ឧបត្ថម្ភដោយ** : រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD)

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........ 1

**១. វាយតម្លៃពីសក្តានុពលទីផ្សារនិងផលិតកម្ម** ........ 2

**១.១.ការចុះសិក្សាតម្រូវការទីផ្សារ និងវិភាគ** ........ 2

គោលបំណង: ........ 2

លទ្ធផលរំពឹងទុក: ........ 2

**១.២. ការវាយតម្លៃពីផលិតកម្មក្នុងសហគមន៍ឆ្លើយតបនឹងតម្រូវការ ទីផ្សារ** ........ 4

**៣. រៀបចំវេទិកាបង្កើតបណ្តុំអាជីវកម្ម** ........ 5

**៤. គាំទ្រសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មបន្ថែម** ........ 5

**៥.រៀបចំកិច្ចសន្យា រវាងក្រុមផលិត និងអ្នកប្រមូលទិញ** ........ 6

**៦.តាមដាន និងវាយតម្លៃ** ........ 7

**៧.តួនាទី និងភារកិច្ចរបស់មន្ត្រីជំនាញ** ........ 7

**៩.ផែនការថវិកា** ........ 9

# សេចក្តីផ្តើម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជានាឆ្នាំ ២០១៥បានបង្ហាញថា ការផ្សព្វផ្សាយកសិកម្មត្រូវផ្លាស់ប្តូរយុទ្ធសាស្រ្តចេញពីការផ្សព្វផ្សាយដែលជម្រុញដោយផ្នែកផ្គង់ផ្គង់ ដើម្បីផលិតកម្មទៅរកការផ្សព្វផ្សាយដើម្បីតម្រូវការទីផ្សារ។ អនុលោមទៅតាមកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលសេវានិងសកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវធ្វើវិមជ្ឈការនៅថ្នាក់មូលដ្ឋាន ដោយពង្រឹងសមត្ថភាពមន្ត្រីនៅថ្នាក់ស្រុកនិងថ្នាក់ឃុំ ជាពិសេសលើការងារធ្វើផែនការ និងការសម្របសម្រួលខ្សែចង្វាក់តម្លៃកសិកម្ម។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)បានចាប់ផ្តើមអនុវត្តពីពាក់កណ្តាលឆ្នាំ២០១៥ដោយអនុវត្តទៅតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជានិងរួមចំណែកក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ កម្មវិធីASPIREអនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាក្នុងខេត្តគោលដៅចំនួនប្រាំ រួមមានៈ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ក្រចេះ និង ព្រះវិហារ នៅជំហានទី១ និងពង្រីកទៅខេត្តប្រាំផ្សេងទៀត ក្នុងឆ្នាំ ២០១៨ រួមមានៈ ខេត្តកណ្តាល កំពត ព្រៃវែង ស្វាយរៀង និង ខេត្តតាកែវ និងខេត្តផ្សេងទៀតចំនួនបី នៅជំហានទី២ ។

**កម្មវិធីASPIREមានគោលបំណងៈ**កាត់បន្ថយភាពក្រីក្រនិងបង្កើនភាពធន់របស់កសិករខ្នាតតូចក្រីក្រនិងងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា ។

**សមិទ្ធផលទី៣ៈ**កសិករសិក្សាខ្នាតតូចយ៉ាងហោចណាស់ចំនួន ១២០.០០០ គ្រួសារ លើកកម្ពស់ការងារធុរកិច្ចកសិកម្មរបស់ខ្លួនប្រកបដោយភាពធន់តាមរយៈការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មនិងការវិនិយោគរបស់កម្មវិធីលើហេដ្ឋារចនាសម្ព័ន្ធដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

**សូចនាករៈ**កសិករខ្នាតតូចយ៉ាងតិច៩០.០០០គ្រួសារដែលប្រកបអាជីវកម្មកសិកម្មបានកើនប្រាក់ចំណេញដោយឆ្លងកាត់ការអនុវត្តបច្ចេកទេសថ្មីដែលបានសិក្សានិងចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្មកម្មវិធីAS PIR។

ដើម្បីសម្រេចបាននូវគោលបំណងនិងសមិទ្ធផលខាងលើកម្មវិធីAS PIRE បានរៀបចំផែនការ យុទ្ធសាស្រ្ត សម្រាប់គាំទ្រកសិករគោលដៅឲ្យមានការលើកកម្ពស់ការងារធុរកិច្ចកសិកម្មរបស់ខ្លួនប្រកបដោយភាពធន់តាមរយៈការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មនិងការជួយស្វែងរកទីផ្សារដោយអនុវត្តទៅតាមជំហានដូចខាងក្រោមៈ

១.ការចុះសិក្សាតម្រូវការទីផ្សារ និងវិភាគ
២.ការប្រជុំ និងពិភាក្សាជាមួយក្រុម ឬសហគមន៍
៣. រៀបចំវេទិការវាងក្រុមផលិត និងអ្នកប្រមូលទិញ

៤.គាំទ្រសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មបន្ថែម
៥. រៀបចំកិច្ចសន្យារវាងអ្នកផលិត និងឈ្មួញ
៦. តាមដាន និងវាយតម្លៃ
៧.តួនាទី និងភារកិច្ចរបស់មន្ត្រីបច្ចេកទេស
៨. ផែនការថវិកា។

# ១. វាយតម្លៃពីសក្តានុពលទីផ្សារនិងផលិតកម្ម

## ១.១.ការចុះសិក្សាតម្រូវការទីផ្សារ និងវិភាគ

**គោលបំណង:**

- សិក្សាតម្រូវការផលិតផលកសិកម្ម (កសិផល) ផ្សេងៗនៅទីផ្សារក្នុងតំបន់ (ឃុំ ស្រុក...)
- យល់ដឹងពីផលលំបាក និងការប្រកួតប្រជែង ក្នុងការជម្រុញផលិតផលក្នុងស្រុក ទៅកាន់ទីផ្សារក្នុងតំបន់
- កំណត់ប្រភេទផលិតកម្ម/អាជីវកម្មកសិកម្ម សម្រាប់ផ្គត់ផ្គង់ទីផ្សារ
- កំណត់អ្នកប្រមូលទិញដើម្បីធ្វើជាដៃគូជាមួយក្រុមឬសហគមន៍សម្រាប់ទីផ្សារ។



**លទ្ធផលរំពឹងទុក:**

- មន្ត្រីនិងបុគ្គលិកពាក់ព័ន្ធបានយល់អំពីនីតិវិធីឬវិធីសាស្ត្រនៃការសិក្សាទីផ្សារ ប្រមូលទិន្នន័យ
- ទិន្នន័យត្រូវបានវិភាគនិងកំណត់ផលិតផលដែលមានសក្តានុពលសម្រាប់តម្រូវការទីផ្សារ
- កំណត់បាននូវដៃគូផ្គត់ផ្គង់ ឬអ្នកប្រមូលទិញចូលរួមដំណើរការទីផ្សារ។



ការចុះសិក្សាៈឃុំ ស្រុក ...គោលដៅដែលមានសក្តានុពលសម្រាប់ផលិត និងផ្គត់ផ្គង់ទីផ្សារ។